# គម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី៣

## ករណីសិក្សា

| | |
|---|---|
| **ស៊ី.ស៊ី.ចេប/ផ្នែក៖**<br>*ទប់ស្កាត់បទល្មើស និងសុវត្ថិភាពសហគមន៍*<br>**បុគ្គលបំពេញទំរង់បែបបទ៖**<br>*ឈ្មោះ ៖ អោមពិសី*<br>*តួនាទី ៖ មន្ត្រីតាមដាននិងត្រួតពិនិត្យ នៃគណៈកម្មាធិការប្រតិបត្តិខេត្តព្រៃវែង* | **កាលបរិច្ឆេទ៖** *ខែមេសា ឆ្នាំ២០១១*<br>**អ្នកដែលត្រូវបានសម្ភាសន៏៖**<br>*ឈ្មោះ ៖ គឿនកាំង អាយុ៖ ១៦ ឆ្នាំ*<br>*ភេទ៖ ប្រុស*<br>*ភូមិ៖ ជាចខាងត្បូង ឃុំ៖ ជាច ស្រុក៖ កំចាយមារ ខេត្ត៖ ព្រៃវែង* |

### ទិសដៅ

*យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រ៤នៃកម្មវិធីទប់ស្កាត់បទល្មើស និងសុវត្ថិភាពសហគមន៍ (ទ.ប.ស.ស) គឺការលើកកំពស់សុខុមាលភាពប្រជាពលរដ្ឋ និងជំរុញឲ្យមានឥរិយាបថល្អៗ សម្រាប់សង្គម តាមរយៈការផ្តល់សេវាផ្នែកសង្គម ផ្នែកសេដ្ឋកិច្ច និងអប់រំ ដោយផ្តោតជាពិសេសទៅលើក្រុមអនីតិជន និងយុវជនដែលមានឥរិយាបថអាចពាក់ព័ន្ធទៅនឹងបទល្មើស ឬរងគ្រោះដោយសារបទល្មើស ។ ករណីសិក្សាខាងក្រោមនេះ គឺជាឧទាហរណ៍មួយនៃការគាំទ្ររបស់គម្រោង ស៊ី.ស៊ី.ចេប ដែលបានចូលរួមចំណែកធ្វើអោយសហគម៌មានភាពរុងរឿងប្រកបដោយបរិស្ថានសុវត្ថិភាព និងសន្តិសុខល្អ។*

### ដំណើររឿង



*កុមារ* ***គឿន កាំង*** *មានអាយុ ១៦ឆ្នាំបានសិក្សាត្រឹមថ្នាក់ទី៦។* ***កាំង*** *គឺជាសមាជិកមួយរូបក្នុងចំណោមសមាជិកទាំង៥របស់គ្រួសារ និងជាកូនបងទី២នៅក្នុងគ្រួសារ។*

*ឪពុកម្តាយរបស់កាំងប្រកបមុខរបរធ្វើស្រែ*

និងចំការដែលមានស្ថានភាពជីវភាពក្រីក្រ។

កុមារកាំង ពុំដែលបានជួយធ្វើការងារនៅផ្ទះទេ ហើយថែមទាំងធ្លាប់គេចសាលាជាញឹកញាប់និងបានទៅសេពគប់ជាមួយក្រុមក្មេងទំនើងផ្សេងទៀតដែលមានអាយុច្រើនជាងខ្លួន។

អាជ្ញាធរមូលដ្ឋានបានធ្វើការសាកសួរនិងអប់រំណែនាំដល់កុមារនេះពាក់ព័ន្ធទៅនឹងការប្រព្រឹត្តខុសឆ្គងរបស់គាត់នៅក្នុងភូមិសហគមន៍ដូចជាការចូលរួមជាមួយក្រុមក្មេងទំនើងផ្សេងទៀតដើម្បីធ្វើការអុកឡុកពីធីបុណ្យផ្សេងៗក្នុងភូមិជាដើម។ ជាលទ្ធផលមិនទទួលបានជោគជ័យ។

## ការជួយអន្តរាគមន៍

ដោយមើលឃើញនូវការប្រព្រឹត្តរបស់កុមារ**កាំង** ក្រុមប្រឹក្សាឃុំសំរេចសាកល្បងជ្រើសរើសកាំងព្រមទាំងធ្វើការណែនាំអោយរៀនសូត្រអំពីបច្ចេកទេសចិញ្ចឹមមាន់។ គំរោង **ទ.ប.ស.ស** បានផ្តល់ជូននូវពូជមាន់ (មេមាន់៣ និងមាន់ឈ្មោល១) ទ្រុងចំណី និងវ៉ាក់សាំង និងគ្រូបង្រៀនអំពីបច្ចេកទេសថែទាំមាន់ ការអោយចំណី អនាម័យទ្រុង និងការព្យាបាល។

ចាប់តាំងពីខែកក្កដាឆ្នាំ២០១០ ដល់បច្ចុប្បន្ន កុមារកាំងមានមាន់ចំនួន៤៥ ទៅ៥០ក្បាល ហើយគាត់បានលក់ដូរមាន់មួយចំនួនកន្លងមកដើម្បីយកកំរៃទិញសំលៀកបំពាក់និងសំភារៈសិក្សា។

## ការផ្លាស់ប្តូរឥរិយាបថ



តាមប្រសាសន៍លោក **ថាច សុខ**ជាស្មៀនឃុំនិងជាអ្នកភូមិមួយរូបរស់នៅក្បែរផ្ទះរបស់កុមារកាំងបាននិយាយថាគាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលកុមាររូបនេះបានផ្លាស់ប្តូរចរិកក្លាយទៅជាមនុស្សល្អ ហើយបានអនុវត្តគំរោងចិញ្ចឹមមាន់នេះបានជោគជ័យ។ លើសពីនេះ កុមារ**កាំង**ក៏

លេងសេពគប់ដើរជាមួយក្រុមក្មេងទំនើងនោះទៀតហើយនិងព្រមទាំងចេះជួយធ្វើការងារផ្ទះដល់ឪពុកម្តាយទៀតផង។ បច្ចុប្បន្នកុមារាកាំងបានត្រឡប់ចូលរៀនវិញហើយកំពុងរៀននៅថ្នាក់ទី៧ឆ្នាំ២០១១នៅក្នុងវិទ្យាល័យទួលសង្កែ។

កុមារាកាំងគឺជាគំរូមួយនៃសមាជិកសហគមន៍វ័យក្មេងដែលបានផ្លាស់ប្តូរជីវិតរបស់គាត់ពីក្មេងទំនើងទៅជាសមាជិកគំរូរបស់សហគមន៍សម្រាប់យុវជនដទៃទៀត។

ការផ្លាស់ប្តូរឥរិយាបថនេះបង្ហាញឲ្យឃើញថាគម្រោង**ទ.ប.ស.ស**ដែលទទួលបានថវិការពីគម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធ៌មកម្ពុជាបានផ្តល់ផលជាវិជ្ជមាននៅក្នុងការកាត់បន្ថយឥរិយាបថ ជួយទប់ស្កាត់បទល្មើស និងការពារអ្នកអាចក្លាយជាអ្នករងគ្រោះ។